គួយ សារុន

ព្រះសង្ឃនិមន្តបិណ្ឌបាត

នៅតាមស្រុកស្រែស្រុកចម្ការ
ពណ៌លឿងភ្លឺថ្លាល្អត្រចះ

ព្រះសង្ឃនិមន្តបិណ្ឌបាត
គួរនឹកដល់អង្គព្រះសម្ពុទ្ធ

នៅតាមទីក្រុងមនុស្សជោរជន់
បិណ្ឌបាតតាមផ្លូវដ៏អ៊ូអរ

ព្រះសង្ឃនិមន្តផ្ទាល់លើដី
សុទ្ធយានជំនិះដិះរៀងខ្លួន

ហ្នឹងហើយក្រុងធំមនុស្សប្តុំប្តើង
នៅស្រែមនុស្សល្ងង់ទាបកន្លង

លេចតាមរុក្ខាមើលឃើញច្បាស់
ឃើញហើយចិត្តជ្រះថ្លាបំផុត។

ឃើញសមស្អាងស្អាតបរិសុទ្ធ
ជាមកុដកំពូលសីលធម៌។

ព្រះសង្ឃនិមន្តត្រេចគោចរ
ឃើញហាក់មិនល្អមិនសមសួន។

អស់លោកប្រុសស្រីខ្មែរចិនយួន
គាប់ជួនពេលខ្លះចង់ប៉ះផង។

ខ្ពង់ខ្ពស់ខ្លាំងឡើងជាចម្បង
តែសមគ្មានឆ្គងក្នុងឥរិយា។

ក្រុងតាកែវ ២៥ សីហា ១៩៦៥

គយ សារុន

ឱដើមអម្ពិលទឹក

គេកាត់គេច្រឹបគេរក្សា
ពីខាង ពីលើ ធ្វើរបង

ស្អិតស្អាងកាយាឲ្យឥតហ្មង
អ្នកផងសរសើរអម្ពិលទឹក ។

ថាជារុក្ខជាតិមានវាសនា
មានដើមមានមែកបន្លាញឹក

គេរាប់ប្រើការបានសន្ធឹក
សន្លឹកក៏ស្រស់រស់យូរយារ ។

តែស្រស់តែស្អាតតែត្រឹមត្រង់
សម្រាប់អម្ពិលទឹករុក្ខា ?

រូបខ្ងង់នេះសម្រាប់នរណា ?
ឬថាសម្រាប់មនុស្សវិញទេ ?

ដើមណាដែលរស់តាមធម្មជាតិ
សារិកាច្រៀវច្រែច្រៀងបំពេ

លូតលាស់តាមមាឌមែកទន់ទេរ
ផ្កាផ្លែរាំរេតាមសូរខ្យល់ ។

ឯដើមឈរត្រៀបតម្រៀបជួរ
តែកំរើកដៃកន្ត្រែដល់

សមគួរល្អគន់ពន់ពេកសល់
បានផលដាច់កត្រដរស់ ។

រស់រាប់ខែឆ្នាំចាំជីវិត
យាមផ្ទះឲ្យគេទទេសោះ

ក្រិនក្រៀមក្រពឹតឥតកម្ពស់
មានឈ្មោះតែត្រង់គេថាល្អ ។

លុះថ្ងៃដែលប្រាក់កាសគេដល់
គេគាស់ទាំងឫសចាក់គ្រឹះថ្ម

គេកាប់គ្មានសល់ពូជទុកត
គេសរសើល្អរបងដៃក ៕

ឆ្នាំ1965

គយ សារុន

សម្រាកមួយភ្លែត

ឈប់សិន! ឈប់សិន! វិទ្យាសាស្ត្រ
ខ្ញុំខំផាយតាមហត់ហួតហែង

ខ្ញុំក្រាលស្លឹកឈើក្រោមម្លប់ស្វាយ
ខ្យល់បក់ល្ហៀកៗល្ហើយកាយា

កាលដើមចង្វាក់នៃជីវិត
រង្វើលៗលយអន្លាយ

រទេះគោបរសូរង៉ើតង៉ត
សូរស័ព្ទសត្វយំឆ្លងឆ្លើយគ្នា

ឯនាយដងទង់ចុងជហ្វា
លេចតាមចន្លោះដើមឈើជុំ

ឯនុះដំណែលប្រាង្គប្រាសាទ
មិនដឹងប៉ុន្មានតដូនតា

កាលគ្មានទឹកកកមនុស្សគិតថា
កាលគ្មានឡានលឿនមនុស្សព្រងើយ

ក្រុងរីកធំឡើងត្រូវទិញខ្យល់
ទិញណាស់ខ្វះណាស់ខ្វល់ស្ទើរស្លាប់

ចម្រើនសម្រាប់តែចម្រើន
ខំលូតនាំហត់អត់បានអ្វី

លឿនណាស់! លឿនណាស់! ចក្រអ្នកឯង
សុំឈប់ប្រជែងផ្កាកចលនា។

ដាក់កាយទម្រេតកើយក្រមា
ចិន្តាហោះហើរហិចទៅឆ្ងាយ ... ។

ហាក់ឥតរន្ទើនក្តៅក្រហាយ
សប្បាយហូរហែរតាមធម្មតា។

ត្រេតត្រតទ្រុយៗកាត់ព្រឹក្សា
កំព្រាដួងចិត្តដូចនេនទុំ។

ដំបូលវិហារកុដមួយដុំ
មើលឃើញជម្រំសមជ្រះថ្លា។

ស្អាងស្អាតសុទ្ធសឹងក្បាច់សិលា
ឥឡូវព្រឹក្សាដុះព័ទ្ធពើយ។

ធឹកទឹកស្រះថ្លាឆ្ងាញ់ណាស់ហើយ
ដើរលេងរហើយគ្មានប្រញាប់។

ទិញសព្វគ្មានសល់គ្រប់ប្រដាប់
ស៊ីណាស់រឹតឆាប់ឃ្លានវិញខ្មី។

គិតទៅគ្មានកើនលើសជាប្មី
គួរតែលែងខ្ជីរត់តាមទៀត។

ឆ្នាំ១៩៦៥

គយ សារុន

បទុមសុរិយាផ្សាយរូប

បទុមសុរិយា
បានព្រះជិនវង្ស
ផ្សងរូបប្រាថ្នា
តាមរករូបស្រី
រួមរស់ស្នេហា ។
រើសរកស្វាមី
ដល់ក្រុងអសុរី

ក្រមុំសម័យ
ញញឹមប្រិមប្រិយ
រាងរៀវច្រវៃ
លើក្របទស្សនា-
ខ្ញុំលួចកើតទុក្ខ ។
បង្ហាញកក្រា
វដ្តីកាលណា

ខ្ញុំសែនស្នេហា
ទាស់ពីគ្មានឫទ្ធិ
ចង់ផ្សងវាសនា
ឬគ្មានទ្រព្យស្តុក
ចិត្តចងស្នងស្នេហ៍ ។
ឱ្យបានជួបមុខ
ក្រែងស្រីមិនសុខ

ម៉្យាងទៀតរូបស្រី
មិនតែរូបមួយ
ផ្សាយពេញផែនដី
ខ្ញុំព្រួយគ្មានល្ហែ
ចងចិត្តប្រចណ្ឌ ។
បុរីនៃខ្មែរ
ក្រែងមានគេដែរ

នាំកើតច្បាំងគ្នា
អួតអាងរាល់ខ្លួន
ដូចជាក្រុងមារ
គុំកួនដុកដាន់
សូមដកខ្លួនថយ ។
យក្សសាលីកណ្ឌ
ខ្ញុំមិនគួចកាន់

ឆ្នាំ 1968